# ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១/០៣/២០០៣
# ស្តីពីការទទួលស្គាល់គុណភាពឧត្តមសិក្សា

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី២៦ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី សហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/១២៩៧/៩១ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៩៧ ស្តីពីលក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានទ្រង់យល់សេចក្តីក្រាបថ្វាយទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

## ត្រាស់បង្គាប់
## ជំពូកទី១ បទបញ្ញត្តិទូទៅ

**មាត្រា១.**

ព្រះរាជក្រឹត្យនេះមានគោលដៅ បង្កើតឱ្យមានយន្តការគតិយុត្តិមួយ សម្រាប់គ្រប់គ្រងការទទួលស្គាល់គុណភាពអប់រំ នៃគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ដើម្បីធានា និងលើកកម្ពស់គុណភាពអប់រំឧត្តមសិក្សាឱ្យមានប្រសិទ្ធភាពខ្ពស់ស្របតាម ស្តង់ដារអន្តរជាតិនិងកំណត់ការរៀបចំរចនាសម្ព័ន្ធ តួនាទីមុខងារ និងភារកិច្ចក្នុងការគ្រប់គ្រង និងការប្រព្រឹត្តទៅនៃការទទួលស្គាល់គុណភាពអប់រំ ចំពោះគ្រឹះស្ថានឧត្តមសិក្សាដែលចេញសញ្ញាប័ត្រ ចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ យន្តការគតិយុត្តិនេះមានឈ្មោះថា គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ហៅកាត់ថា **គ.ទ.ក** ។

**មាត្រា២.**

គ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់ការអប់រំចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវឆ្លងកាត់ការទទួលស្គាល់គុណភាពអប់រំ ។ ដើម្បីបានការទទួលស្គាល់គុណភាពអប់រំ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវឆ្លងកាត់ការវាយតម្លៃលើប្រព័ន្ធគ្រប់គ្រងគុណភាពសិក្សា និងកម្មវិធីសិក្សា ។ មានតែគ្រឹះស្ថានឧត្តមសិក្សា ដែលបានទទួលស្គាល់គុណភាពអប់រំទេ ទើបអាចចេញសញ្ញាប័ត្របរិញ្ញាបរិញ្ញាបត្រជាន់ខ្ពស់ និងបណ្ឌិតបាន ។

**មាត្រា៣.**

ការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ដែលមិនទាន់មានការទទួលស្គាល់គុណភាពអប់រំពី **គ.ទ.ក** ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់ក្រសួងអប់រំ យុវជន និងកីឡា ។ គ្រឹះស្ថានឧត្តមសិក្សាទាំងនោះ ត្រូវរៀបចំសំណុំបែបបទសុំការទទួលស្គាល់គុណភាពអប់រំ ពី **គ.ទ.ក** ក្នុងរយៈពេល ៣ ខែ បន្ទាប់ពីថ្ងៃដែលគ្រឹះស្ថានឧត្តមសិក្សាទាំងនោះចាប់ពីដំណើរការ ។

## ជំពូកទី២ ការប្រព្រឹត្តទៅនៃការទទួលស្គាល់គុណភាពអប់រំ

**មាត្រា៤.**

គ្រឹះស្ថានឧត្តមសិក្សា ដែលផ្តល់ការអប់រំចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ នៅក្នុងព្រះរាជាណាចក្រ

កម្ពុជាត្រូវគោរពតាមការប្រព្រឹត្តទៅនៃការទទួលស្គាល់គុណភាពអប់រំ ។ ការផ្តល់ការទទួលស្គាល់គុណភាពអប់រំ ត្រូវធ្វើឡើងតាមរយៈការវាយតម្លៃ ដោយយកស្តង់ដារគុណភាពអប្បបរមាមូលដ្ឋាន មកធ្វើជាលក្ខណវិនិច្ឆ័យ លើគ្រឹះស្ថានឧត្តមសិក្សា ឬកម្មវិធីសិក្សា នៃគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ ។ ស្តង់ដារគុណភាពអប្បបរមា មូលដ្ឋានសម្រាប់ផ្តល់ការទទួលស្គាល់គុណភាពអប់រំ លើគ្រឹះស្ថានឧត្តមសិក្សា គឺជាការវាយតម្លៃទៅលើកិច្ចប្រតិបត្តិការងារនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដូចមានចែងក្នុងមាត្រា៩នៃព្រះរាជក្រឹត្យនេះ ។ **គ.ទ.ក** ត្រូវរៀបចំបែបបទលំអិត ដើម្បីកំណត់អំពីស្តង់ដារគុណភាពអប្បបរមាមូលដ្ឋាននេះ ។

**មាត្រា៥.**

ការទទួលស្គាល់គុណភាពអប់រំ ចំពោះគ្រឹះស្ថានឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជា មានកម្រិតដូចខាងក្រោម ៖

- ការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន ដល់គ្រឹះស្ថានឧត្តមសិក្សាដែលកំពុងដំណើរការបច្ចុប្បន្ន
- ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ

**មាត្រា៦.**

ការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន ត្រូវមានការអនុញ្ញាតពី **គ.ទ.ក** និងត្រូវផ្តល់ឱ្យដល់គ្រឹះស្ថានឧត្តមសិក្សាកំពុងដំណើរការបច្ចុប្បន្ន ដែលបំពេញបាននូវចំណុចគោល នៃស្តង់ដារគុណភាពអប្បបរមា និងមានផែនការច្បាស់លាស់ ក្នុងការបំពេញឱ្យបាននូវស្តង់ដារគុណភាពអប្បបរមា ដែលកំណត់ដោយ **គ.ទ.ក** ។ ជាគោលការណ៍ក្នុងរយៈពេលបីឆ្នាំ បន្ទាប់ពីបានការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្នគ្រឹះស្ថានឧត្តមសិក្សានោះ ត្រូវបំពេញឱ្យបានតាមស្តង់ដារគុណភាពអប់រំ ដើម្បីទទួលបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ។ គ្រឹះស្ថានឧត្តមសិក្សាដែលបានការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន អាចរក្សាឈ្មោះបច្ចុប្បន្នរបស់ខ្លួនដដែលបាន ។ គ្រឹះស្ថានឧត្តមសិក្សា ដែលបានការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន ត្រូវធ្វើរបាយការណ៍អំពីវឌ្ឍនភាព និងការរីកចម្រើនរបស់ខ្លួនរាល់ឆ្នាំជូនទៅ **គ.ទ.ក** ។

**មាត្រា៧.**

គ្រឹះស្ថានឧត្តមសិក្សាដែលកំពុងដំណើរការបច្ចុប្បន្ន និងការទទួលស្គាល់គុណភាពអប់រំឈ្មោះអាសន្នត្រូវផ្តល់ឯកសារបញ្ជាក់ឱ្យបានច្បាស់លាស់អំពីវិធានការ ដែលត្រូវបំពេញ ក្នុងរយៈពេលសមស្របដែលកំណត់ដោយ **គ.ទ.ក** ដើម្បីឱ្យមានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ។ ផ្អែកលើមូលហេតុសមស្រប **គ.ទ.ក** អាចពន្យារ ការទទួលស្គាល់គុណភាពអប់រំបណ្តោះអាសន្ន ដល់គ្រឹះស្ថានឧត្តមសិក្សាទាំងឡាយណា ដែលមិនបានបំពេញលក្ខខណ្ឌ សម្រាប់ការទទួលស្គាល់គុណភាពអប់រំបំពេញសិទ្ធិ ទាន់ពេលវេលា ។

**មាត្រា៨.**

ការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ត្រូវផ្តល់ជូនចំពោះគ្រឹះស្ថានឧត្តមសិក្សាទាំងឡាយណាដែលបានបំពេញស្តង់ដារអប្បបរមា នៃការទទួលស្គាល់គុណភាពអប់រំ តាមការកំណត់របស់ **គ.ទ.ក** ។

**មាត្រា៩.**

**គ.ទ.ក** ត្រូវបរិយាយលំអិតអំពីលក្ខខណ្ឌសម្រាប់កំណត់ តម្រូវការចាំបាច់នៃស្តង់ដារអប្បបរមាសម្រាប់គ្រប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់នៅព្រះរាជាណាចក្រកម្ពុជា ដោយរាប់បញ្ចូលកត្តាសំខាន់ៗដូចខាងក្រោម ៖

ក. បេសកកម្ម

- សេចក្តីបញ្ជាក់ច្បាស់លាស់អំពីបេសកកម្មនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ
- ផ្សារភ្ជាប់ជាមួយនឹងការចូលរួមក្នុងការអភិវឌ្ឍន៍សង្គមកម្ពុជា

**ខ. រចនាសម្ព័ន្ធ គ្រប់គ្រង ការគ្រប់គ្រង និងគម្រោងផែនការ**

- ភារកិច្ចទទួលខុសត្រូវ រចនាសម្ព័ន្ធ គ្រប់គ្រង និងសមាជិកភាពនៃក្រុមប្រឹក្សាភិបាល
- ដំណើរការនៃផែនការយុទ្ធសាស្ត្រ
- តួនាទីនិងភារកិច្ច របស់សកលវិទ្យាធិការ ឬព្រឹទ្ធបុរស ឬនាយក
- រចនាសម្ព័ន្ធ និងអង្គការលេខផ្ទៃក្នុង
- គណៈកម្មការគ្រប់គ្រងផ្ទៃក្នុង

**គ. កម្មវិធីសិក្សា**

- ខ្លឹមសារ និងការរៀបចំកម្មវិធីសិក្សា
- ប្រសិទ្ធភាពនៃការបង្រៀន
- ការរៀបចំកម្មវិធីសិក្សាតាមប្រព័ន្ធក្រេឌីត និងដំណើរការក្នុងការផ្ទេរក្រេឌីតសិក្សា
- គោលការណ៍សម្រាប់វាយតម្លៃនិស្សិត
- ការរៀបចំឱ្យមានយន្តការទទួលខុសត្រូវ និងវិធានក្នុងទទួលយកព័ត៌មានពីមជ្ឈដ្ឋានពាក់ព័ន្ធ
- ការស្រាវជ្រាវ
- ប្រព័ន្ធធានាគុណភាពផ្ទៃក្នុង

**ឃ. បុគ្គលិកសិក្សា**

- គុណវុឌ្ឍិ និងបទពិសោធន៍របស់បុគ្គលិក
- ការអភិវឌ្ឍបុគ្គលិក
- ការរៀបចំប្រាក់បំណាច់ និងកាំប្រៀវត្ស
- កិច្ចសន្យាការងារជាមួយបុគ្គលិក
- ការតែងតាំង និងដំឡើងឋានៈបុគ្គលិក

**ង. និស្សិត និងសេវាសម្រាប់និស្សិត**

- គោលការណ៍ក្នុងការជ្រើសរើសនិស្សិត
- មុខវិជ្ជាចាំបាច់
- ការកំណត់ថ្ងៃ សិក្សាសម្រាប់និស្សិត
- ដំណើរការផ្តល់អាហារូបករណ៍
- សេវាផ្សេងៗ ដូចជាការផ្តល់អន្តេវាសិកដ្ឋាន ការកម្សាន្ត និងកីឡា
- ការផ្តល់សេវាសហគមន៍

**ច. សេវាសិក្សា**

- បណ្ណាល័យ បន្ទប់ពិសោធន៍ សម្ភារៈ ឧបករណ៍ និងធនធាន ផ្សេងៗទៀត
- ការផ្តល់បច្ចេកវិទ្យាព័ត៌មាន

**ឆ. ទីតាំងសម្ភារៈរូបវន្ត**

- ការគ្រប់គ្រងសម្ភារៈរូបវន្ត
- ចំនួនថ្នាក់រៀន និងទំហំថ្នាក់រៀននីមួយៗ
- ការរៀបចំការថែទាំ
- បទដ្ឋាន អំពីសុខភាព សុវត្ថិភាព និងសន្តិសុខ
- សម្ភារៈរូបវន្តសម្រាប់ការប្រាស្រ័យទាក់ទង

- ផ្សេងៗ

**ជ. គម្រោងផែនការ និងការគ្រប់គ្រងថវិកា**

- ការរៀបចំគម្រោងថវិកា និងផែនការ
- ការរៀបចំប្រព័ន្ធសវនកម្ម

**ឈ. ការផ្សព្វផ្សាយព័ត៌មាន**

- ការរៀបចំ អភិបាលកិច្ច
- ព័ត៌មាន អំពីអាហារូបករណ៍
- សេចក្តីសម្រេចរបស់ថ្នាក់ដឹកនាំ
- ឯកសារ និងព័ត៌មានសម្រាប់កម្មវិធីសិក្សា
- ព័ត៌មានស្តីពីថ្ងៃ សិក្សា

ស្តង់ដារអេប្បបរមាដទៃទៀតនឹងកំណត់ដោយ **គ.ទ.ក** ។

**មាត្រា១០ថ្មី** (ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២/០២/២០០៥)

**គ.ទ.ក** មានសមាជិកអចិន្ត្រៃយ៍ និងសមាជិកជ្រើសតាំង ។

**ក. សមាជិកអចិន្ត្រៃយ៍**

សមាជិកអចិន្ត្រៃយ៍រួមមាន រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា ។ ឥស្សរជនទាំងពីររូបត្រូវធ្វើជាប្រធាន ឬអនុប្រធាន **គ.ទ.ក** ។ ឥស្សរជនដែលមានតំណែងខ្ពស់ជាងក្នុងរាជរដ្ឋាភិបាល ត្រូវធ្វើជាប្រធាន **គ.ទ.ក** ហើយឥស្សរជន ដែលមានតំណែងទាបជាងត្រូវធ្វើជាអនុប្រធាន **គ.ទ.ក** ។ ក្នុងករណីដែលឥស្សរជនទាំងពីរមានតំណែងស្មើគ្នាក្នុងរាជរដ្ឋាភិបាលប្រធាន **គ.ទ.ក** ត្រូវជ្រើសរើសតាមរយៈពេលការបោះឆ្នោតរបស់សមាជិកជ្រើសតាំងទាំងប្រាំរូប ដោយសំឡេងភាគច្រើនដាច់ខាតហាសិបបូក មួយ ។

**ខ. សមាជិកជ្រើសតាំង**

សមាជិកជ្រើសតាំងមានប្រាំរូប ដែលត្រូវជ្រើសរើសចេញពីឥស្សរជនកម្ពុជាដែលមានសញ្ញាប័ត្រឧត្តមសិក្សា និងមានជំនាញផ្នែកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ឬមានជំនាញក្នុងកសាងគោលនយោបាយ ផ្នែកឧត្តមសិក្សាតាមរយៈនីតិវិធីដូចបានកំណត់ក្នុងមាត្រា១៥ថ្មី និង១៦ថ្មី នៃព្រះរាជក្រឹត្យនេះ ឬមាត្រា៦២ នៃព្រះរាជក្រឹត្យលេខនស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា ។

**គ.ទ.ក** មានជំនាញពីររូប ដែលមានបទពិសោធន៍នៅក្នុងស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៃប្រទេសនានាជាទីប្រឹក្សា ។

~~**មាត្រា១០.**~~

~~**គ.ទ.ក** ត្រូវមានសមាសភាពដូចខាងក្រោម ៖~~

~~- រដ្ឋមន្ត្រី ក្រសួងអប់រំ យុវជន និងកីឡា..........................................................ប្រធាន~~

~~- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី...........................................អនុប្រធានអចិន្ត្រៃយ៍~~

~~- ឥស្សរជនកម្ពុជាដែលមានសញ្ញាប័ត្រឧត្តមសិក្សា និងមានជំនាញផ្នែកគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ឬមានជំនាញ ក្នុងការកសាងគោលនយោបាយផ្នែកឧត្តមសិក្សា ចំនួនប្រាំរូប...ជាសមាជិក~~

~~**គ.ទ.ក** មានអ្នកជំនាញពីររូប ដែលមានពិសោធន៍នៅក្នុងស្ថាប័នទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សានៃប្រទេសនានាជាទីប្រឹក្សា ។~~

**មាត្រា១១ថ្មី** (ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២/០២/២០០៥)

សមាជិក **គ.ទ.ក** ទាំងអស់ត្រូវជ្រើសតាំងឱ្យបម្រើការងារមិនពេញម៉ោង និងទទួលប្រាក់ឧបត្ថម្ភតាម

រយៈពេលទីស្តីការគណៈរដ្ឋមន្ត្រី ។ ប្រាក់ឧបត្ថម្ភរបស់សមាជិក **គ.ទ.ក** ត្រូវកំណត់ដោយអនុក្រឹត្យតាមសំណើរបស់ប្រធាន **គ.ទ.ក** ។

**គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយចំណុះផ្ទាល់ទីស្តីការគណៈរដ្ឋមន្ត្រី ។ អគ្គលេខាធិការដ្ឋាន **គ.ទ.ក** ដឹកនាំដោយអគ្គលេខាធិការ១រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងអមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការតាមការចាំបាច់ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ទ.ក** នឹងកំណត់ដោយអនុក្រឹត្យ ។

**គ.ទ.ក** មានបទបញ្ជាផ្ទៃក្នុង ឡូហ្គោ និងត្រាមួយដោយឡែករបស់ខ្លួន ។

~~**មាត្រា១១.**~~

~~សមាជិក **គ.ទ.ក** ទាំងអស់ ត្រូវជ្រើសតាំងឱ្យបម្រើការងារមិនពេញម៉ោងនិងទទួលប្រាក់ឧបត្ថម្ភតាមរយៈទីស្តីការគណៈរដ្ឋមន្ត្រី ។~~

~~**គ.ទ.ក** មានអគ្គលេខាធិការដ្ឋានមួយ ដឹកនាំដោយអគ្គលេខាធិការ១រូបមានឋានៈស្មើអនុរដ្ឋលេខាធិការ និងអមដោយលេខាធិការរងមួយចំនួនជាជំនួយការ តាមការចាំបាច់ ។ សមាសភាព ការរៀបចំ និងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃ **គ.ទ.ក** នឹងកំណត់ដោយអនុក្រឹត្យ ។~~

~~**គ.ទ.ក** មានបទបញ្ជាផ្ទៃក្នុង និងត្រាមួយដោយឡែករបស់ខ្លួន ។~~

**មាត្រា១២.**

**គ.ទ.ក** មានសិទ្ធិជ្រើសរើសអ្នកឯកទេស ដែលមានជំនាញផ្សេងៗ មកបម្រើការងារក្នុងការវាយតម្លៃការទទួលស្គាល់គុណភាពអប់រំតាមផ្នែកនីមួយៗបាន ។ អ្នកឯកទេសទាំងនេះត្រូវរៀបចំជាអនុគណៈកម្មការជំនាញស្ថិតក្រោម **គ.ទ.ក** ។ ក្នុងករណីគ្រឹះស្ថានឧត្តមសិក្សាណាមួយ មានក្រសួង ឬស្ថាប័នរដ្ឋជាអាណាព្យាបាល ក្រៅពីក្រសួងអប់រំយុវជន និងកីឡា រដ្ឋមន្ត្រី ឬតំណាងស្របច្បាប់នៃក្រសួង ឬស្ថាប័នរដ្ឋជាអាណាព្យាបាលនោះ ត្រូវអញ្ជើញឱ្យចូលរួមក្នុងអនុគណៈកម្មការជំនាញនេះ ។

**មាត្រា១៣ថ្មី** (ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២/០៣/២០០៩)

សមាជិក គ.ទ.ក មានអាណត្តិបីឆ្នាំ ហើយអាចត្រូវជ្រើសតាំងបន្តរយៈពេលបីឆ្នាំទៀតបាន តាមរយៈការតែងតាំង ឬតាមរយៈការបោះឆ្នោត ដែលអនុវត្តតាមនីតិវិធីកំណត់ក្នុងព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការកែសម្រួលមាត្រា១០ មាត្រា១១ មាត្រា១៤ មាត្រា១៥ និងមាត្រា១៦ នៃអនុក្រឹត្យស្តីពីការទទួលគុណភាពអប់រំឧត្តមសិក្សា ។

~~**មាត្រា១៣.**~~

~~សមាជិក **គ.ទ.ក** មានអាណត្តិបីឆ្នាំ ហើយអាចត្រូវជ្រើសរើសតាំងបន្តរយៈពេលបីឆ្នាំទៀតបាន ។~~

**មាត្រា១៤ ថ្មី.** (ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២/០២/២០០៥)

ដើម្បីជ្រើសតាំងសមាជិក **គ.ទ.ក** ប្រធាន **គ.ទ.ក** ត្រូវបង្កើតគណៈកម្មការស្នើតាំងមួយសម្រាប់ជ្រើសតាំងបេក្ខភាពតំណាងសមាជិក **គ.ទ.ក** ។ ដើម្បីឱ្យដំណើរការជ្រើសតាំងនេះប្រព្រឹត្តទៅបានប្រសិទ្ធភាពខ្ពស់ ប្រធាន **គ.ទ.ក** ត្រូវជូនដំណឹងទៅគណៈកម្មការស្នើតាំងឱ្យធ្វើការស្នើតាំងបេក្ខជនសម្រាប់តំណែងសមាជិក **គ.ទ.ក** ។

~~**មាត្រា១៤.**~~

~~ដើម្បីជ្រើសតាំងសមាជិក **គ.ទ.ក** ក្រសួងអប់រំ យុវជន និងកីឡា ត្រូវបង្កើតគណៈកម្មការស្នើតាំងមួយសម្រាប់ជ្រើសតាំងបេក្ខជនតំណែងសមាជិក **គ.ទ.ក** ។ ដើម្បីឱ្យដំណើរការជ្រើសតាំងនេះប្រព្រឹត្តទៅបានប្រសិទ្ធភាពខ្ពស់ ក្រសួងអប់រំ យុវជន និងកីឡា ត្រូវជូនដំណឹងទៅ គណៈកម្មការស្នើតាំងឱ្យធ្វើការស្នើតាំងបេក្ខជនសម្រាប់តំណែងសមាជិក **គ.ទ.ក** ។~~

**មាត្រា១៥. ថ្មី** (ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២/០២/២០០៥)

ក្នុងការជ្រើសតាំងបេក្ខភាពតំណែងសមាជិក **គ.ទ.ក** គណៈកម្មការស្នើតាំង ត្រូវធ្វើការជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយយកសំឡេងភាគច្រើនដាច់ខាតហាសិបបូកមួយ ។ បន្ទាប់មក គណៈកម្មការនេះត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតប្រាំរូបទៅ ប្រធាន **គ.ទ.ក ។** ផ្អែកលើបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតនោះ ប្រធាន **គ.ទ.ក** ត្រូវរៀបចំស្នើតែងតាំងសមាជិក **គ.ទ.ក** ដោយព្រះរាជក្រឹត្យ ។ គណៈកម្មការស្នើតាំងក៏មានភារកិច្ចធ្វើការស្នើតាំងសមាសភាពថ្មីផងដែរ ពេលណាតំណែងនៃសមាជិក**គ.ទ.ក** ណាមួយដែលទំនេរ ។

~~**មាត្រា១៥.**~~

~~ក្នុងការជ្រើសរើសតាំងបេក្ខភាពតំណែងសមាជិក **គ.ទ.ក** គណៈកម្មការស្នើតាំង ត្រូវធ្វើការជ្រើសតាំងតាមរយៈការបោះឆ្នោត ដោយយកសំឡេងភាគច្រើនដាច់ខាត (៥០%+១) ។ បន្ទាប់មក គណៈកម្មការនេះ ត្រូវបញ្ជូនបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោត ប្រាំរូបទៅក្រសួងអប់រំ យុវជន និងកីឡា ។ ផ្អែកលើបញ្ជីឈ្មោះបេក្ខជនជាប់ឆ្នោតនោះក្រសួងអប់រំ យុវជន និង ត្រូវរៀបបែបបទស្នើសុំតែងតាំង សមាជិក **គ.ទ.ក** ដោយព្រះរាជក្រឹត្យ ។ គណៈកម្មការស្នើតាំងក៏មានភារកិច្ចធ្វើការស្នើតាំងសមាសភាពថ្មីផងដែរពេលណាមានតំណែងនៃសមាជិក **គ.ទ.ក** ណាមួយដែលទំនេរ ។~~

**មាត្រា១៦. ថ្មី** (ព្រះរាជក្រឹត្យលេខ នស/រកត/០២០៥/០៩៧ ចុះថ្ងៃទី២២/០២/២០០៥)

សមាសភាពនៃគណៈកម្មការស្នើតាំងមានដូចតទៅ ៖

- តំណាងទីស្តីការគណៈរដ្ឋមន្ត្រីមួយរូប ............................................................ ប្រធាន
- តំណាងក្រសួងអប់រំ យុវជន និងកីឡាមួយរូប ................................................... អនុប្រធាន
- សកលវិទ្យាធិការ ឬព្រឹទ្ធបុរស ឬនាយកនៃគ្រឹះស្ថានឧត្តមសិក្សាដែលទទួលស្គាល់អនុញ្ញាតជាផ្លូវការពីរាជរដ្ឋាភិបាលមួយរូប ............................................................................... សមាជិក
- តំណាងក្រសួងអាណាព្យាបាលនៃគ្រឹះស្ថានឧត្តមសិក្សា នីមួយៗ ................................ សមាជិក

គណៈកម្មការស្នើតាំងមានសិទ្ធិអញ្ជើញឱ្យចូលរួមជាអ្នកអង្កេតការណ៍ ៖

- តំណាងម្ចាស់ជំនួយបរទេស ដែលនាំមុខគេផ្នែកឧត្តមសិក្សាបីរូប
- តំណាងមកពីភ្នាក់ងារសាកលវិទ្យាល័យភាសាបារាំង AUF បីរូប
- តំណាងមកពីបណ្តាញសមាគមសាកលវិទ្យាល័យអាស៊ានASEAN University  Network ១រូប
- តំណាងមកពីអង្គការស៊ីម៉េអូរ៉ាយហេត SEAMEO RIHED មួយរូប ។

~~**មាត្រា១៦.**~~

~~សមាសភាពនៃគណៈកម្មការស្នើតាំងមានដូចតទៅ ៖~~

- ~~តំណាងក្រសួងអប់រំ យុវជន និងកីឡាមួយរូប ............................................................ ប្រធាន~~
- ~~សកលវិទ្យាធិការ ឬព្រឹទ្ធបុរស ឬនាយកនៃគ្រឹះស្ថានឧត្តមសិក្សា ដែលទទួលស្គាល់ដោយក្រសួងអប់រំ យុវជន និងកីឡា នៅក្នុងព្រះរាជាណាចក្រកម្ពុជាមួយរូប ក្នុងគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ............................................................................................................... សមាជិក~~
- ~~តំណាងក្រសួងអាណាព្យាបាលនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ...................................... សមាជិក~~
- ~~តំណាងទីស្តីការគណៈរដ្ឋមន្ត្រី................................................................................. សមាជិក~~

~~គណៈកម្មការស្នើតាំងមានសិទ្ធិអញ្ជើញ ៖~~

- ~~តំណាងម្ចាស់ជំនួយបរទេស ដែលនាំមុខគេផ្នែកឧត្តមសិក្សាបីរូប~~
- ~~តំណាងមកពីភ្នាក់ងារសាកលវិទ្យាល័យប្រើភាសាបារាំង AUF មួយរូប~~
- ~~តំណាងមកពីបណ្តាញសមាគមសាកលវិទ្យាល័យអាស៊ាន ASEAN University Network មួយរូប~~
- ~~តំណាងមកពីអង្គការស៊ីម៉េអូរ៉ាយហេត SEAMEO RIHED មួយរូប មកចូលរួមក្នុងដំណើរការស្នើ~~

~~តាំងសមាជិក គ.ទ.ក ។~~

**មាត្រា១៧.**

គ្រប់គ្រឹះស្ថានឧត្តមសិក្សា ដែលមានបំណងផ្តល់ការអប់រំ ចាប់ពីថ្នាក់បរិញ្ញាបត្រឡើងទៅ ត្រូវបំពេញ និងធានាឱ្យមានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ។ គ្រឹះស្ថានឧត្តមសិក្សា ដែលបានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិ ហើយមានបំណងបង្កើតកម្មវិធីសិក្សាថ្មី ក៏ត្រូវគោរពតាមនីតិវិធី ក្នុងការទទួលស្គាល់គុណភាពភាពអប់រំនេះផងដែរ ។ **គ.ទ.ក** ត្រូវកំណត់ល័ក្ខខ័ណ្ឌចាំបាច់ សម្រាប់ការទទួលស្គាល់គុណភាពអប់រំ រួមទាំងល័ក្ខខ័ណ្ឌនានាខាងលើ ក្នុងការទទួលស្គាល់គុណភាពអប់រំ ស្របតាមបទប្បញ្ញត្តិនៃព្រះរាជក្រឹត្យនេះ ។

**មាត្រា ១៨.**

រាល់ព័ត៌មានស្តីពីកម្រិតនៃការទទួលស្គាល់គុណភាពអប់រំ ត្រូវធ្វើការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយជាសាធារណៈ ។ សាធារណៈជនមានសិទ្ធិទទួលបានព័ត៌មានទាំងនេះ ។ ក្រសួងអប់រំ យុវជន និងកីឡាមានភារកិច្ចផ្សព្វផ្សាយព័ត៌មានអំពីស្ថានភាពនៃគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដល់គ្រប់គ្រឹះស្ថានសិក្សា នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ **គ.ទ.ក** មានភារកិច្ចផ្សព្វផ្សាយលទ្ធផលគំហើញរបស់ខ្លួនសម្រាប់សាធារណជន។ គ្រឹះស្ថានឧត្តមសិក្សាក៏មានកាតព្វកិច្ចប្រកាសផ្សាយជាសាធារណៈ ដោយបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកម្រិត នៃការទទួលស្គាល់គុណភាពអប់រំ ដែលគ្រឹះស្ថានឧត្តមសិក្សារបស់ខ្លួន បានទទួលពី **គ.ទ.ក** ផងដែរ ។

**មាត្រា១៩.**

របាយការណ៍ប្រចាំឆ្នាំ របស់គ្រឹះស្ថានឧត្តមសិក្សាដែលដាក់ជូន **គ.ទ.ក** ត្រូវផ្ញើជូនទៅក្រសួងអប់រំ យុវជន និងកីឡាមួយច្បាប់ រក្សាទុកក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនមួយច្បាប់ និងមួយច្បាប់ទៀត យកទៅតម្កល់ទុកនៅប័ណ្ណសារដ្ឋានជាតិ ។

**មាត្រា២០.**

នីតិវិធី និងរបៀបរបបធ្វើការងាររបស់ **គ.ទ.ក** ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ ។ រាល់សេចក្តីសម្រេចផ្លូវការរបស់ **គ.ទ.ក** ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ និងតាមរយៈការសម្រេចដោយមតិភាគច្រើនដាច់ខាត (៥០ +១) ។

**មាត្រា២១.**

**គ.ទ.ក** មានមុខងារនិងភារកិច្ចដូចខាងក្រោម ៖

- កំណត់គោលនយោបាយ នៃការទទួលស្គាល់គុណភាពអប់រំ និងវិធានការចាំបាច់នានា ដើម្បីធានាគុណភាពអប់រំ សម្រាប់គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា
- កំណត់កម្រិតការទទួលស្គាល់គុណភាពអប់រំ ចំពោះគ្រឹះស្ថានឧត្តមសិក្សា
- ផ្តល់ការយល់ព្រមលើកម្មវិធីសិក្សាឆ្នាំមូលដ្ឋាន ចំពោះនិស្សិតឆ្នាំទីមួយនៃគ្រឹះស្ថានឧត្តមសិក្សានានា
- រក្សាទុកឯកសារកត់ត្រា នៃការវាយតម្លៃចំពោះគ្រឹះស្ថានសិក្សា និងកម្មវិធីសិក្សា និងសកម្មភាពនៃការធានាគុណភាពអប់រំ ក្នុងគ្រឹះស្ថានឧត្តមសិក្សានីមួយៗ
- ធ្វើការវាយតម្លៃ ចំពោះគ្រឹះស្ថានឧត្តមសិក្សា ដោយផ្អែកលើមូលដ្ឋាននៃការចុះអង្កេត
- ទាក់ទងជាមួយស្ថាប័នជាតិ និងអន្តរជាតិដែលពាក់ព័ន្ធទៅនឹងការទទួលស្គាល់គុណភាពអប់រំ និងការធានាគុណភាពអប់រំ
- ធានាឱ្យមានការចូលរួម សមស្របពីអ្នកពាក់ព័ន្ធ ទាក់ទងនឹងលទ្ធផល របស់គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ដែលបានដាក់ពាក្យសុំការទទួលស្គាល់គុណភាពអប់រំ

- ផ្សព្វផ្សាយជាសាធារណៈនូវលទ្ធផលគំហើញរបស់ **គ.ទ.ក** ក្នុងកិច្ចការងារនៃការទទួលស្គាល់គុណភាពអប់រំ

**គ.ទ.ក** ត្រូវវាយតម្លៃ និងផ្តល់ការទទួលស្គាល់គុណភាពអប់រំ ឡើងវិញរៀងរាល់ប្រាំឆ្នាំម្តង ដល់គ្រឹះស្ថានឧត្តមសិក្សាទាំងឡាយណា ដែលមានការទទួលស្គាល់គុណភាពអប់រំពេញសិទ្ធិរួមហើយ ។

**មាត្រា២២.**

គ្រឹះស្ថានឧត្តមសិក្សាបរទេសណាមួយ ដែលមានបំណងផ្តល់ការអប់រំ និងចេញសញ្ញាប័ត្រឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជា ត្រូវស្នើសុំការទទួលស្គាល់គុណភាពអប់រំ ពី **គ.ទ.ក** និងត្រូវឆ្លងកាត់តាមបែបបទដូចគ្នានឹងគ្រឹះស្ថានឧត្តមសិក្សាកម្ពុជាផងដែរ ។ គ្រឹះស្ថានឧត្តមសិក្សាបរទេសអាចអនុញ្ញាតឱ្យធ្វើកិច្ចសហការជាមួយ គ្រឹះស្ថានឧត្តមសិក្សាកម្ពុជា ដែលមានការទទួលស្គាល់គុណភាពអប់រំ ពី **គ.ទ.ក** ប្រសិនបើ គ្រឹះស្ថានឧត្តមសិក្សាបរទេសនោះ មានការទទួលស្គាល់ ដោយរដ្ឋាភិបាល ឬដោយស្ថាប័នទទួលស្គាល់គុណភាពអប់រំនៅក្នុងសាមីប្រទេស ។

## ជំពូកទី៣
## ការធានាគុណភាពអប់រំ

**មាត្រា២៣.**

ការធានាគុណភាពអប់រំ ជាមធ្យោបាយសម្រាប់ឱ្យគ្រឹះស្ថានឧត្តមសិក្សាទាំងអស់ អាចបញ្ជាក់ថា ស្តង់ដារទាំងឡាយដែលខ្លួនបានកំណត់ត្រូវធានា និងធ្វើឱ្យប្រសើរឡើងជាលំដាប់ ។ ការធានាគុណភាពអប់រំ នៅព្រះរាជាណាចក្រកម្ពុជា ត្រូវមានរូបភាពទ្វេ គឺការវាយតម្លៃផ្ទៃក្នុងផង និងការវាយតម្លៃផ្លូវការពីខាងក្រៅផង ។

**មាត្រា ២៤.**

ការវាយតម្លៃក្នុង គឺជាដំណើរការ នៃការធានាគុណភាពអប់រំ ដែលគ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវពិនិត្យឡើងវិញយ៉ាងទៀងទាត់ នូវស្តង់ដារប្រចាំឆ្នាំរបស់ខ្លួន ដើម្បីធានាថា ទិសដៅ នៃការបង្រៀន ការរៀន និងការស្រាវជ្រាវ និងទិសដៅដទៃទៀត ត្រូវបានបំពេញតាមការកំណត់ ។ **គ.ទ.ក** ត្រូវផ្តល់ការណែនាំបន្ថែម លើដំណើរការវាយតម្លៃផ្ទៃក្នុងនេះ ។

**មាត្រា២៥.**

ការវាយតម្លៃជាផ្លូវការពីខាងក្រៅ ត្រូវធ្វើឡើងផ្អែកលើរបាយការណ៍នៃគ្រឹះស្ថានឧត្តមសិក្សា ដែលបានជូនទៅ **គ.ទ.ក** អំពីវឌ្ឍនភាពឈានទៅសម្រេចគោលបំណងរបស់គ្រឹះស្ថានឧត្តមសិក្សានោះ និងឈានទៅកែលំអចំណុចខ្វះខាតទាំងឡាយ ដែលកត់សម្គាល់ដោយ **គ.ទ.ក** នៅក្នុងដំណើរការ នៃការទទួលស្គាល់គុណភាពអប់រំ ។

**មាត្រា២៦.**

គ្រឹះស្ថានឧត្តមសិក្សានីមួយៗមានកាតព្វកិច្ច ធ្វើការផ្សព្វផ្សាយជាសាធារណៈ អំពីលទ្ធផល នៃការធានាគុណភាពអប់រំ ដែលខ្លួនសម្រេចបានក្នុងឆ្នាំនីមួយៗ ។ ការផ្សព្វផ្សាយព័ត៌មានទាំងនេះ ដល់សាធារណជន ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរក្នុងទម្រង់ ដែលច្បាស់លាស់ និងងាយយល់ ។

## ជំពូកទី៤
## ការកំណត់កម្មវិធីសិក្សាអប្បបរមា

**មាត្រា២៧.**

កម្មវិធីសិក្សា គឺជាការប្រមូលផ្តុំនូវមុខវិជ្ជាសិក្សាមួយ ឬ ច្រើននៅក្នុងមុខជំនាញឯកទេសទាំងឡាយនៃការសិក្សាដើម្បីឈានទៅទទួលសញ្ញាប័ត្រឧត្តមសិក្សា ។

**មាត្រា២៨.**

ដើម្បីទទួលបានសញ្ញាប័ត្របរិញ្ញា ដំបូងនិស្សិតត្រូវបញ្ចប់ការសិក្សាថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានរយៈពេលមួយឆ្នាំនៃការសិក្សាពេញម៉ោង ឬ រយៈពេលសមមូលនៃការសិក្សាមិនពេញម៉ោង ។ និស្សិតដែលបញ្ចប់ឆ្នាំសិក្សាមូលដ្ឋាននេះ ត្រូវទទួលបានវិញ្ញាបនបត្រឆ្នាំសិក្សាមូលដ្ឋាន ។ និស្សិត ត្រូវបន្តការសិក្សាពេញម៉ោង ឬ មិនពេញម៉ោងតាមកម្មវិធី ដែលផ្អែកលើប្រព័ន្ធក្រេឌីត ដែលមានការទទួលស្គាល់ ទើបអាចទទួលសញ្ញាប័ត្របរិញ្ញាបាន ។

**មាត្រា២៩.**

លក្ខខណ្ឌសម្រាប់ការចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវកំណត់ដោយគ្រឹះស្ថានឧត្តមសិក្សានីមួយៗ ស្របតាមការណែនាំរបស់ **គ.ទ.ក** ដោយចាត់ទុកជាផ្នែកមួយ នៃដំណើរការទទួលស្គាល់គុណភាពអប់រំ របស់គ្រឹះស្ថានឧត្តមសិក្សានោះ ។ ការចូលសិក្សាថ្នាក់ឆ្នាំមូលដ្ឋាន ត្រូវផ្អែកលើលទ្ធផល នៃការប្រឡងយកសញ្ញាប័ត្រ មធ្យមសិក្សាទុតិយភូមិរបស់និស្សិតម្នាក់ៗ ។ ក្រោយពីមានការយល់ព្រមពី **គ.ទ.ក** គ្រឹះស្ថានឧត្តមសិក្សានីមួយៗអាចកំណត់លក្ខខណ្ឌ សម្រាប់និស្សិតវ័យចំណាស់ និងនិស្សិតមកពីគ្រឹះស្ថានមធ្យមសិក្សាបច្ចេកទេសនានា ឬគ្រឹះស្ថានសិក្សាក្រោយមធ្យមសិក្សាទុតិយភូមិផ្សេងទៀត ឱ្យចូលសិក្សានៅក្នុងគ្រឹះស្ថានសិក្សារបស់ខ្លួនបាន ។

**មាត្រា ៣០ថ្មី.** (ព្រះរាជក្រឹត្យលេខ នស/រកត/០៣០៩/២៤៣ ចុះថ្ងៃទី០២/០៣/២០០៩)

ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានមុខវិជ្ជា ដែលស្រង់ចេញពីវិស័យសិក្សាទាំងបួនផ្នែកដូចខាងក្រោម ៖

- សិល្បៈ និងមនុស្សសាស្ត្រ
- គណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា
- វិទ្យាសាស្ត្រសង្គម
- ភាសាបរទេស

ចំនួនក្រេឌីតនៃមុខវិជ្ជាក្នុងវិស័យនីមួយៗ ត្រូវមានយ៉ាងតិច១០ភាគរយនៃពិន្ទុក្រេឌីតសរុបសម្រាប់វិញ្ញាបនបត្រថ្នាក់សិក្សាមូលដ្ឋាន។ មុខវិជ្ជាដែលនិស្សិតជ្រើសរើសនៅក្នុងឆ្នាំសិក្សាមូលដ្ឋាន ត្រូវស្របទៅនឹងផ្នែកជំនាញដែលនិស្សិតជ្រើសរើស ប៉ុន្តែនិស្សិតត្រូវសិក្សាមុខវិជ្ជាចាំបាច់ សម្រាប់ចូលសិក្សានៅថ្នាក់បរិញ្ញាបត្រ ។

~~**មាត្រា៣០.**~~

~~ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានត្រូវមានមុខវិជ្ជាដែលស្រង់ចេញវិស័យសិក្សាទាំងបួនផ្នែកដូចខាងក្រោម ៖~~

~~- សិល្បៈ និងមនុស្សសាស្ត្រ~~
~~- គណិតសាស្ត្រ វិទ្យាសាស្ត្រ និងកុំព្យូទ័រវិទ្យា~~
~~- វិទ្យាសាស្ត្រសង្គម~~
~~- ភាសាបរទេស~~

~~មុខវិជ្ជានីមួយៗក្នុងវិស័យទាំងបួន ត្រូវមានយ៉ាងតិច ២០% នៃពិន្ទុក្រេឌីតសរុប សម្រាប់វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ។ មុខវិជ្ជាដែលនិស្សិតជ្រើសរើសនៅក្នុងឆ្នាំសិក្សាមូលដ្ឋាន ត្រូវស្របទៅនឹងផ្នែកជំនាញដែលនិស្សិតជ្រើសរើស ប៉ុន្តែនិស្សិតត្រូវតែសិក្សាមុខវិជ្ជាចាំបាច់សម្រាប់ការចូលរួមសិក្សានៅថ្នាក់បរិញ្ញាបត្រផងដែរ ។~~

**មាត្រា៣១.**

មុខវិជ្ជាខាងក្រោមនេះត្រូវបានដាក់បញ្ចូលក្នុងវិស័យសិល្បៈ និងមនុស្សសាស្ត្រ ៖

- អក្សរសាស្ត្រ
- ប្រវត្តិសាស្ត្រ

- ទស្សនវិជ្ជា
- វិចិត្រសិល្បៈ
- តូរ្យតន្រ្តី
- បុរាណវិទ្យា
- ការសិក្សាពីសាសនា
- ខេមរៈសិក្សា

មុខវិជ្ជាដទៃទៀតដែលយល់ព្រមពី **គ.ទ.ក** ។

**មាត្រា៣២.**

មុខវិជ្ជាខាងក្រោមនេះត្រូវបានដាក់បញ្ចូលក្នុងវិស័យគណិតសាស្រ្ត វិទ្យាសាស្រ្ត និងកុំព្យូទ័រវិទ្យា ៖

- គណិតវិទ្យា
- គីមីវិទ្យា
- ជីវវិទ្យា
- រូបវិទ្យា
- ភូគព្ភសាស្រ្ត
- ការសិក្សាអំពីបរិស្ថាន
- វិទ្យាសាស្រ្តអនុវត្ត
- កុំព្យូទ័រវិទ្យា

មុខវិជ្ជាដទៃទៀតដែលយល់ព្រមពី **គ.ទ.ក** ។

**មាត្រា៣៣.**

មុខវិជ្ជាខាងក្រោមនេះ ត្រូវដាក់បញ្ចូលក្នុងវិស័យវិទ្យាសាស្រ្តសង្គម ៖

- វិទ្យាសាស្រ្តនយោបាយ
- រដ្ឋបាលសាធារណៈ
- សង្គមវិទ្យាសាស្រ្ត និងនរវិទ្យា
- ចិត្តវិទ្យា
- សេដ្ឋកិច្ចវិទ្យា
- ភូមិវិទ្យា
- ប្រជាសាស្រ្ត

មុខវិជ្ជាដទៃទៀតដែលយល់ព្រមពី **គ.ទ.ក** ។

**មាត្រា៣៤.**

មុខវិជ្ជាខាងក្រោមនេះ ត្រូវដាក់បញ្ចូលក្នុងផ្នែក ភាសាបរទេស ៖

- ភាសាអង់គ្លេស
- ភាសាបារាំង
- ភាសាដទៃទៀត

**មាត្រា៣៥.**

គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវសុំការអនុញ្ញាតពី **គ.ទ.ក** ដើម្បីចេញវិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ។ ដើម្បីទទួលការអនុញ្ញាតនេះ គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវមានសមត្ថភាពក្នុងស្រូបយកនិស្សិត ឱ្យចូលរៀនថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ពេញម៉ោងយ៉ាងតិច ៥០០ នាក់ ឬ ចំនួនសមមូល នៃនិស្សិតចូលរៀនមិនពេញម៉ោង ។ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវរៀបចំឡើងដោយដេប៉ាតឺម៉ង់ នៃថ្នាក់ឆ្នាំសិក្សាមូល

ដ្ឋាន នៅក្នុងគ្រឹះស្ថានឧត្តមសិក្សានោះ ។ វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានមុខវិជ្ជាស្របតាម ការកំណត់នៃព្រះរាជក្រឹត្យនេះ ។

**មាត្រា៣៦.**

គ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់លក្ខខណ្ឌវិនិច្ឆ័យ សម្រាប់ជ្រើសរើសនិស្សិតឱ្យចូលរៀនថ្នាក់បរិញ្ញាបត្រ ។ លក្ខណវិនិច្ឆ័យនេះ ត្រូវបញ្ចូលទាំងការប្រឡងជាប់វិញ្ញាបនបត្រ ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានផងដែរ ។ ក្នុងករណីពិសេស គ្រឹះស្ថានឧត្តមសិក្សា អាចអនុញ្ញាតឱ្យនិស្សិត ដែលមានវិញ្ញាបនបត្រ បញ្ជាក់ការសិក្សាក្រោយមធ្យមសិក្សាទុតិយភូមិ មកពីគ្រឹះស្ថានសិក្សាផ្សេងៗ ចូលសិក្សាថ្នាក់បរិញ្ញាបត្របាន ។ ករណីពិសេសនេះ ត្រូវមានការយល់ព្រមពី **គ.ទ.ក** ។

**មាត្រា៣៧.**

គ្រឹះស្ថានឧត្តមសិក្សាទាំងអស់ ត្រូវរៀបចំកម្មវិធីសិក្សាដោយផ្អែកលើប្រព័ន្ធក្រេឌីត ។ ដើម្បីទទួលបានបរិញ្ញាបត្រ វិញ្ញាបនបត្រថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ឬសញ្ញាប័ត្រកម្រិតខ្ពស់ជាងនេះ និស្សិតត្រូវបំពេញឱ្យបានគ្រប់ចំនួនក្រេឌីត ក្នុងមុខវិជ្ជាទាំងឡាយ ដែលកំណត់ដោយគ្រឹះស្ថានឧត្តមសិក្សាទាំងនោះ ។

**មាត្រា៣៨.**

កម្មវិធីសិក្សាសម្រាប់កម្រិតសញ្ញាប័ត្រឧត្តមសិក្សា និងថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ត្រូវមានមុខវិជ្ជាផ្សេងៗ ដែលមានចំនួនក្រេឌីតជាក់លាក់ ។ ជាទូទៅ តម្លៃមួយក្រេឌីត ស្មើនឹងការបង្រៀនមួយម៉ោងក្នុងមួយសប្តាហ៍រយៈពេលមួយឆមាស ។ ចំពោះមុខវិជ្ជាទាក់ទិននឹងការអនុវត្តជាក់ស្តែង រយៈពេលសិក្សាអាចច្រើនជាងនេះ ។ **គ.ទ.ក** ត្រូវកំណត់បែបបទ និងផ្តល់ការណែនាំបន្ថែម ស្តីពីការរៀបចំប្រព័ន្ធក្រេឌីតនេះ។

**មាត្រា៣៩.**

ប្រព័ន្ធក្រេឌីត គឺជាយន្តការសម្រាប់សម្រួលដល់ការសិក្សា មិនពេញម៉ោង ឬការបញ្ចូលគ្នានូវការសិក្សាពេញម៉ោងផងដែរ និងការសិក្សាមិនពេញម៉ោងផង ។

## ជំពូកទី៥
## ការផ្ទេរក្រេឌីតសិក្សា

**មាត្រា៤០.**

ការផ្ទេរក្រេឌីត គឺជាការទទួលស្គាល់ជាផ្លូវការ របស់គ្រឹះស្ថានឧត្តមសិក្សាមួយ លើមុខវិជ្ជាទាំងឡាយដែលនិស្សិតបានបញ្ចប់ដោយជោគជ័យ នៅក្នុងគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀត ។

**មាត្រា៤១.**

គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវទទួលស្គាល់ក្រេឌីត ពីគ្រឹះស្ថានឧត្តមសិក្សាមួយផ្សេងទៀត ដែលមានការទទួលស្គាល់គុណភាពអប់រំ ។ ក៏ប៉ុន្តែ ការសម្រេចចុងក្រោយទាក់ទងនឹងការផ្ទេរក្រេឌីតនេះ ជាសិទ្ធិរបស់គ្រឹះស្ថានឧត្តមសិក្សា ដែលជាអ្នកទទួលយកក្រេឌីតនោះប៉ុណ្ណោះ។ **គ.ទ.កប** ត្រូវរៀបចំបែបបទ ក្នុងការផ្ទេរក្រេឌីតដើម្បីសម្រួលដំណើរការនេះ ។

## ជំពូក ៦
## ការកំណត់ប្រភេទគ្រឹះស្ថានឧត្តមសិក្សា

**មាត្រា៤២.**

ប្រភេទនៃគ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ដោយអនុក្រឹត្យ ស្តីពីលក្ខណវិនិច្ឆ័យ នៃការបង្កើតសាកលវិទ្យាល័យ ។

## ជំពូកទី៧
## អាហារូបករណ៍

**មាត្រា៤៣.**

គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ ឬគ្រឹះស្ថានឧត្តមសិក្សាឯកជន អាចផ្តល់អាហារូបករណ៍ឱ្យដល់និស្សិតដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ។ អាហារូបករណ៍ អាចបានមកពីប្រភពផ្សេងៗ ។ ចំពោះគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ មូលនិធិសម្រាប់អាហារូបករណ៍ដល់និស្សិត អាចផ្តល់ដោយរាជរដ្ឋាភិបាល និងប្រភពផ្សេងៗទៀត ។

**មាត្រា៤៤.**

អាហារូបករណ៍សម្រាប់និស្សិតមានបីប្រភេទដូចតទៅ ៖

- ប្រភេទទី១ ៖ សម្រាប់សិស្សពូកែ
- ប្រភេទទី២ ៖ សម្រាប់និស្សិតដែលមានសមត្ថភាព ប៉ុន្តែក្រីក្រពុំមានលទ្ធភាពបន្តការសិក្សាបាន
- ប្រភេទទី៣ ៖ សម្រាប់និស្សិតដែលសិក្សាលើមុខជំនាញ ដែលរាជរដ្ឋាភិបាលកំណត់ថាជាមុខជំនាញអាទិភាព ឬមុខជំនាញចាំបាច់សម្រាប់សង្គម ។

ក្នុងការផ្តល់អាហារូបករណ៍ដល់និស្សិត កត្តាសំខាន់ត្រូវយកចិត្តទុកដាក់គឺ សមធម៌យេនឌ័រ ទីតាំងភូមិសាស្ត្រ និងក្រុមជនជាតិភាគតិច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤៥.**

ដើម្បីឱ្យមានតម្លាភាព ក្នុងការគ្រប់គ្រង និងការផ្តល់អាហារូបករណ៍ដល់និស្សិតមានប្រសិទ្ធភាពខ្ពស់គ្រប់គ្រឹះស្ថានឧត្តមសិក្សា ត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ នូវបញ្ជីឈ្មោះនិស្សិត ដែលគ្រឹះស្ថានឧត្តមសិក្សានោះបានផ្តល់អាហារូបករណ៍ឱ្យ ។

## ជំពូកទី

## រចនាសម្ព័ន្ធគ្រប់គ្រងគ្រឹះស្ថានសិក្សា

**មាត្រា៤៦.**

ក្រសួងអប់រំយុវជន និងកីឡា មានភារកិច្ចទទួលខុសត្រូវចំពោះការគ្រប់គ្រង ផ្នែកអប់រំឧត្តមសិក្សានៅក្នុងព្រះរាជាណាចក្រកម្ពុជា ។ ក្រសួងអប់រំ យុវជន និងកីឡា មានភារកិច្ចរៀបចំគ្រឹះស្ថានឧត្តមសិក្សាទាំងឡាយដែលមាននៅក្នុងក្របខ័ណ្ឌរបស់ខ្លួន ឱ្យក្លាយជាគ្រឹះស្ថានសិក្សាមានស្វយ័តភាព ស្របតាមបទបញ្ញត្តិនៃព្រះរាជក្រឹត្យស្តីពី លក្ខន្តិកៈគតិយុត្តិ នៃគ្រឹះស្ថានសាធារណៈរដ្ឋបាល ។

**មាត្រា៤៧.**

ក្រសួងអប់រំយុវជន និងកីឡា ត្រូវរៀបចំបែបបទ និងអនុក្រឹត្យគំរូដើម្បីសម្រួលដល់ដំណើរការ នៃការរៀបចំគ្រឹះស្ថានឧត្តមសិក្សា ឱ្យទៅជាគ្រឹះស្ថានសិក្សាមានស្វយ័តភាព ដូចមានចែងក្នុងមាត្រា៤៦ខាងលើ ។ បទប្បញ្ញត្តិនៃអនុក្រឹត្យគំរូនេះ ត្រូវស្របតាមស្តង់ដារអប្បបរមា សម្រាប់ការគ្រប់គ្រងគ្រឹះស្ថានសិក្សាដែលរៀបចំដោយ **គ.ទ.ក** ។

**មាត្រា៤៨.**

ដើម្បីបានទៅជាគ្រឹះស្ថានឧត្តមសិក្សាមានស្វយ័តភាព គ្រឹះស្ថានឧត្តមសិក្សានីមួយៗត្រូវ ៖

ក- មានក្រុមប្រឹក្សាភិបាល ដែលមានសមាជិកមកពី គ្រឹះស្ថានឧត្តមសិក្សាសាមី ស្ថាប័នរាជរដ្ឋាភិបាល និងស្រទាប់ សង្គមស៊ីវិល ។

ខ- មានការទទួលខុសត្រូវលើ ៖

- ការរៀបចំ និងការអនុវត្តកម្មវិធីសិក្សា
- ការគ្រប់គ្រងថវិកា
- ការគ្រប់គ្រងបុគ្គលិក
- ការកំណត់ថ្លៃសិក្សា
- ការគ្រប់គ្រងទ្រព្យសម្បត្តិ

- ការងារលទ្ធកម្ម

គ- មានការទទួលខុសត្រូវ តាមរយៈរបាយការណ៍ប្រចាំឆ្នាំ ជូនទៅក្រសួងអប់រំ យុវជន និងកីឡា និងជូនទៅ **គ.ទ.ក** ។ របាយការណ៍នេះ ត្រូវធ្វើលំអិតអំពីសកម្មភាព និងការងារហិរញ្ញវត្ថុ របស់គ្រឹះស្ថានឧត្តមសិក្សានោះ ។

**មាត្រា៤៩.**

**គ.ទ.ក** ត្រូវពិនិត្យឡើងវិញជាប្រចាំលើការរៀបចំ សម្រាប់ការគ្រប់គ្រងគ្រឹះស្ថានឧត្តមសិក្សា ដើម្បីធានាឱ្យមានការគោរពតាមស្តង់ដារអប្បបរមា ។

## ជំពូកទី៩
## ថវិកា

**មាត្រា៥០.**

ចំពោះគ្រឹះស្ថានឧត្តមសិក្សា ដែលមានក្រសួង ឬ ស្ថាប័នអាណាព្យាបាល ហើយទទួលបានថវិការដ្ឋពីក្រសួង ឬស្ថាប័នអាណាព្យាបាល គ្រឹះស្ថានឧត្តមសិក្សានោះអាចបន្តទទួលថវិកាពីក្រសួង ឬស្ថាប័ននោះ រហូតទាល់តែគ្រឹះស្ថានឧត្តមសិក្សានោះ ក្លាយជាគ្រឹះស្ថានឧត្តមសិក្សាស្វយ័ត ។ គ្រឹះស្ថានឧត្តមសិក្សា ខាងលើអាចទទួលបានមូលនិធិពីប្រភពផ្សេងៗទៀតបាន ដូចជាជំនួយទ្វេភាគី ពហុភាគី និងជំនួយអង្គការក្រៅរដ្ឋាភិបាល ហើយមានសិទ្ធិកំណត់ និងទទួលយកថ្លៃសិក្សាពីនិស្សិត និងការលក់សេវាកម្មផ្សេងៗទៀតបាន ។

**មាត្រា៥១.**

គ្រឹះស្ថានឧត្តមសិក្សា ដែលមានស្វ័យភាព អាចទទួលមូលនិធិពីប្រភពផ្សេងៗទៀតបាន ដូចជាជំនួយពីរាជរដ្ឋាភិបាល ជំនួយទ្វេភាគី ពហុភាគី និងជំនួយពីអង្គការក្រៅរដ្ឋាភិបាល ។ គ្រឹះស្ថានឧត្តមសិក្សាទាំងនេះមានសិទ្ធិកំណត់ និងទទួលយកថ្លៃសិក្សាពីនិស្សិត និងថ្លៃលក់សេវាកម្មផ្សេងៗបាន ។ មូលនិធិដែលបានផ្តល់ពីរាជរដ្ឋាភិបាល ត្រូវដាក់បញ្ចូលទៅក្នុងគម្រោងថវិការបស់ក្រសួង ឬស្ថាប័នដែលជាអាណាព្យាបាល ។ មូលនិធិនេះ ត្រូវផ្តល់តាមរយៈជំពូកទី១០ស្តីពីប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភរបស់មន្ត្រីរាជការ និងជំពូកទី៣១ ស្តីពីអាហារូបករណ៍ ។ ចំពោះជំពូកថវិកាបច្ចុប្បន្ន ដែលមានចែងក្នុងជំពូកទី១១ និងជំពូកទី១៣ របស់រាជរដ្ឋាភិបាល ត្រូវដាក់បញ្ចូលទៅក្នុងជំពូកទី៣១ ។ ចំពោះថវិកាដែលបានកាត់បន្ថយ ដោយមូលហេតុចំនួនមន្ត្រីរាជការបានថយចុះ ជំពូកទី១០ត្រូវយកទៅដាក់បញ្ចូលជំនួសវិញក្នុងជំពូកទី៣១នៃអន្តរាគមន៍ផ្នែកសង្គមកិច្ច(អាហារូបករណ៍) ។

**មាត្រា៥២.**

ថវិកាសរុបក្នុងជំពូកទី១០ និងទី៣១ ដែលមានចែងក្នុងកថាខណ្ឌចុងក្រោយ នៃមាត្រា៥១ ខាងលើត្រូវយកទៅប្រើប្រាស់សម្រាប់ការចំណាយលើថ្លៃ អាហារូបករណ៍ ។ ចំនួនអាហារូបករណ៍ ត្រូវកំណត់ស្របទៅនឹងថ្លៃសិក្សាសម្រាប់និស្សិតម្នាក់ៗនៅគ្រឹះស្ថានសិក្សានីមួយៗ ។ សកលវិទ្យាធិការ ឬនាយកនៃគ្រឹះស្ថានឧត្តមសិក្សា ត្រូវកំណត់ថ្លៃពិតប្រាកដប្រចាំឆ្នាំសម្រាប់និស្សិតម្នាក់ៗ ។

**មាត្រា៥៣.**

ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរួមគ្នាកំណត់អំពីចំនួនអាហារូបករណ៍ ដែលត្រូវផ្តល់ឱ្យគ្រឹះស្ថានសិក្សាក្នុងឆ្នាំនីមួយៗ ។ ចំនួនអាហារូបករណ៍ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរ ដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សានីមួយៗបានដឹងមុនធ្វើការជ្រើសរើស ។

**មាត្រា៥៤.**

គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវមានផែនការយុទ្ធសាស្ត្រប្រាំឆ្នាំរបស់ខ្លួន ជូនទៅក្រសួង ឬស្ថាប័នអាណាព្យាបាល នៅក្នុងខែកញ្ញានៃឆ្នាំនីមួយៗ រួមទាំងគម្រោងថវិកាលំអិតនៃឆ្នាំដំបូងដែរ ។ គម្រោង

ថវិកាលំអិតនេះ ត្រូវបង្ហាញពីថវិកាចំណូល ដូចជាប្រាក់បានមកពីការបង់ថ្លៃសិក្សារបស់និស្សិត និងប្រាក់ចំណាយផ្សេងៗ ដូចជាការបន្ថែមប្រាក់បៀវត្សជូនមន្ត្រីរាជការ និង ប្រាក់បៀវត្សសម្រាប់បុគ្គលិកជាប់កិច្ចសន្យា ព្រមទាំងរបាយការណ៍លំអិតនៃការងាររលទ្ធកម្ម។

**មាត្រា៥៥.**

ក្រសួង ឬស្ថាប័នអាណាព្យាបាលមានរយៈពេលបួនសប្តាហ៍ ដើម្បីពិចារណាលើគម្រោងថវិកា ហើយត្រូវលើកជាបញ្ហាវិញបើសិនជាមាន ។ ក្នុងករណីក្រសួង ឬស្ថាប័នអាណាព្យាបាល ពុំបានជំទាស់ទៅនឹងគម្រោងថវិការបស់គ្រឹះស្ថានឧត្តមសិក្សានោះ ក្នុងរយៈពេលបួនសប្តាហ៍ទេ គ្រឹះស្ថានឧត្តមសិក្សានោះចាត់ទុកថាក្រសួង ឬស្ថាប័នអាណាព្យាបាល បានយល់ព្រមលើគម្រោងថវិការបស់ខ្លួនរួចរាល់ហើយ និងពុំតម្រូវឱ្យមានការយល់ព្រមបន្ទាប់ទៀត លើគម្រោងថវិកានេះឡើយ ។

**មាត្រា៥៦.**

ក្នុងករណី មានការឯកភាពលើគម្រោងថវិកា គ្រឹះស្ថានឧត្តមត្រូវសិក្សាបញ្ជូនគម្រោងថវិការបស់ខ្លួនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីឱ្យគ្រឹះស្ថានឧត្តមសិក្សានោះ អាចទទួលថវិការបស់ខ្លួនដោយផ្ទាល់បានស្របតាម គម្រោងថវិកាជំពូកទី១០ និងជំពូកទី៣១ របស់រាជរដ្ឋាភិបាល ។

**មាត្រា៥៧.**

គ្រឹះស្ថានឧត្តមសិក្សានីមួយៗ ត្រូវបញ្ជូនរបាយការណ៍ថវិកាប្រចាំឆ្នាំ ដោយបញ្ជាក់ពីការអនុវត្តថវិការបស់ខ្លួនជូនទៅក្រសួង ឬស្ថាប័នដែលជាអាណាព្យាបាលយ៉ាងយូរប្រាំបីសប្តាហ៍ក្រោយបំណាច់ឆ្នាំនីមួយៗ ។

**មាត្រា៥៨.**

អចលនវត្ថុ ដីធ្លី និងអាគារសាធារណៈរបស់រដ្ឋបច្ចុប្បន្ន ដែលគ្រប់គ្រងដោយគ្រឹះស្ថានឧត្តមសិក្សា ត្រូវស្ថិតជាទ្រព្យសម្បត្តិរបស់រដ្ឋ ។ គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ និងក្រុមប្រឹក្សាភិបាលរបស់ខ្លួន ត្រូវទទួលខុសត្រូវក្នុងការថែរក្សាអចលនទ្រព្យឱ្យបានល្អប្រសើរ ។ ក្នុងករណីគ្រឹះស្ថានឧត្តមសិក្សាមានផែនការសាងសង់អាគារថ្មី គ្រឹះស្ថានឧត្តមសិក្សានោះត្រូវស្នើសុំការអនុញ្ញាតសាងសង់តាមរយៈការអនុម័តគម្រោងថវិការបស់រាជរដ្ឋាភិបាល ។

## ជំពូកទី១០
## គ្រឹះស្ថានឧត្តមសិក្សាឯកជន

**មាត្រា៥៩.**

គ្រឹះស្ថានឧត្តមសិក្សាឯកជន ត្រូវឆ្លងកាត់ការទទួលស្គាល់គុណភាពអប់រំ និងត្រូវគោរពការធានាគុណភាពអប់រំដូចគ្នា នឹងគ្រឹះស្ថានឧត្តមសិក្សាសាធារណៈដែរ ។ ដើម្បីទទួលបានការទទួលស្គាល់គុណភាពអប់រំ គ្រឹះស្ថានឧត្តមសិក្សា ឯកជនត្រូវបំពេញបែបបទជូន **គ.ទ.ក** ដែលជារួមត្រូវ ៖

- ផ្តល់ផែនការយុទ្ធសាស្ត្រ សម្រាប់ការអភិវឌ្ឍគ្រឹះស្ថានឧត្តមសិក្សារបស់ខ្លួន ដើម្បីរួមចំណែកលើស្ទួយ វិស័យឧត្តមសិក្សានៅព្រះរាជាណាចក្រកម្ពុជា
- ផ្តល់គម្រោងគ្រប់គ្រងលំអិត រួមមានសមាជិកភាព និងវិធានក្នុងការជ្រើសតាំងក្រុមប្រឹក្សាដែលរួមមាន តំណាងមកពីស្រទាប់សង្គមស៊ីវិល
- ផ្តល់ល័ក្ខខ័ណ្ឌក្នុងការជ្រើសតាំងសកលវិទ្យាធិការ ឬព្រឹទ្ធបុរស ឬនាយកគ្រឹះស្ថានសិក្សារបស់ខ្លួន
- ផ្តល់វិធានការក្នុងការរៀបចំ និងគ្រប់គ្រងទ្រព្យសម្បត្តិ និងហិរញ្ញវត្ថុរបស់គ្រឹះស្ថានសិក្សារបស់ខ្លួន
- ផ្តល់របាយការណ៍ប្រចាំឆ្នាំស្តីពីសកម្មភាព និងការងារហិរញ្ញវត្ថុ និងត្រូវរក្សាឯកសារទាំងនេះសម្រាប់សាធារណជន ។

**មាត្រា៦០.**

គ្រឹះស្ថានឧត្តមសិក្សាឯកជននីមួយៗ អាចជួលអចលនវត្ថុ ដីធ្លី និងអាគាររបស់រដ្ឋបាន ។ ថ្លៃឈ្នួលត្រូវមានការឯកភាពរវាងគ្រឹះស្ថានឧត្តមសិក្សាឯកជននោះ ជាមួយរាជរដ្ឋាភិបាល និងត្រូវស្របនឹងចំនួនអាហារូបករណ៍ដែលគ្រឹះស្ថានឧត្តមសិក្សាឯកជននោះ បានផ្តល់ឱ្យនិស្សិត ។ គ្រឹះស្ថានឧត្តមសិក្សាឯកជន អាចមានសិទ្ធិ គ្រប់គ្រង និងសាងសង់លើដីធ្លី ដែលខ្លួនបានជួលពីរដ្ឋ បើសិនជាមានការអនុញ្ញាតពីរាជរដ្ឋាភិបាល ។

## ជំពូកទី១១
## ប្រភពធនធានរបស់ គ.ទ.ក

**មាត្រា៦១.**

**គ.ទ.ក** មានខ្ទង់ថវិកាមួយដោយឡែក ដែលជាឧបសម្ព័ន្ធ នៃថវិការបស់ទីស្តីការគណៈរដ្ឋមន្ត្រី។ ធនធានថវិការបស់ **គ.ទ.ក** បានមកពីការផ្គត់ផ្គង់របស់ថវិកាជាតិ និងពីប្រភពផ្សេងៗទៀត ។

## ជំពូកទី១២
## អន្តរប្បញ្ញត្តិ

**មាត្រា៦២.**

ដើម្បីរៀបចំការប្រព្រឹត្តទៅ នៃការទទួលស្គាល់គុណភាពអប់រំ ក្នុងព្រះរាជាណាចក្រកម្ពុជាមានប្រសិទ្ធភាពខ្ពស់ និងទាន់ពេលវេលា រាជរដ្ឋាភិបាល និងធ្វើការរៀបចំ **គ.ទ.ក** ក្នុងអាណត្តិដំបូង ។

## ជំពូកទី១៣
## អវសានប្បញ្ញត្តិ

**មាត្រា៦៣.**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះត្រូវទុកជានិរាករណ៍ ។

**មាត្រា៦៤.**

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ។

**មាត្រា៦៥.**

ព្រះរាជក្រឹត្យនេះចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣

**ក្នុងនាមព្រះបរមនាម និងតាមព្រះរាជាគ្រាស់បង្គាប់**

**ប្រមុខរដ្ឋស្តីទី**

**ហត្ថលេខា និងត្រា**

**ជា ស៊ីម**